ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៦ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩.០២.៩៦ ព្រះរាជក្រឹត្យ រកត/ជស/០២៩៦/០៣ តែងតាំងលោក មុត ខៀវ ជានាយករងខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ២ ៣៦២

II ទីស្ដីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

១៣.០២.៩៦ អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៦៣

១៣.០២.៩៦ អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៦៤

III ការងារបណ្ដាក្រសួង

១–ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២.០២.៩៦ ប្រកាសលេខ ០១១ ប្រក. បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និង ប្រគល់កិច្ចសន្យារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៣៦៦

១២.០២.៩៦ ប្រកាសលេខ ០១២ សហវ.លស.ប្រក ស្ដីពីការបង្កើតគណៈកម្មាធិការ បែងចែកតាមប្រភេទ និង ចំណាត់ថ្នាក់អ្នកទទួលការសាងសង់ ៣៦៨

១២.០២.៩៦ ប្រកាសលេខ ០១៣ ប្រក.សហវ.ថ ស្ដីពីការណែនាំអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៧ អនក្រ ចុះថ្ងៃទី ៣១ ខែ មេសា ឆ្នាំ ១៩៩៦ ចំណាយជាគុណប្រយោជន៍ខេត្ត–ក្រុង ៣៧០

១២.០២.៨៦ ប្រកាសលេខ ០១៤ ប្រក.ស ហវថ ស្ដីពីការប្រគល់គាតព្វកិច្ច ចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៨៦ ៣៧១

២—ឯកសារក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

១៣.០២.៨៦ ប្រកាសលេខ ៨៨ ផក.ប្រក អនុញ្ញាតអោយលោក អ៊ឹង ស៊ីផាត ជនជាតិខ្មែរសញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ៣៧៣

១៣.០២.៨៦ ប្រកាសលេខ ៨៩ ផក.ប្រក អនុញ្ញាតអោយលោក ហាក់ ប៊ុនឈឹម ជនជាតិខ្មែរសញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ៣៧៣

១៣.០២.៨៦ ប្រកាសលេខ ៩០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ប្រាក់ សុខុម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ២៤ សេះ ៣៧៤

១៣.០២.៨៦ ប្រកាសលេខ ៩១ ផក.ប្រក អនុញ្ញាតអោយលោក ចាវ ខេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតស្រាស សញ្ញា « ផ្កាឈូក » ៣៧៤

១៣.០២.៨៦ ប្រកាសលេខ ៩២ ផក.ប្រក អនុញ្ញាតអោយលោក ជន់ ឆេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធសញ្ញា « សេះស » ៣៧៥

១៣.០២.៨៦ ប្រកាសលេខ ៩៣ ផក.ប្រក អនុញ្ញាតអោយលោក ចោង ស្រូយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឡផលិតឥដ្ឋក្បឿង ៣៧៥

១៣.០២.៨៦ ប្រកាសលេខ ៩៤ ផក.ប្រក អនុញ្ញាតអោយលោក ហួយ អ៊ឹម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ៣៧៦

ឥ

១៣.០២.៩៦ ប្រកាសលេខ ៩៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អ៊ីវ សុធា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរសិប្បកម្មកាត់ដេរ សំលៀកបំពាក់ ៣៧៦

១៣.០២.៩៦ ប្រកាសលេខ ៩៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ស៊ីវ លី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរសិប្បកម្មផលិតទឹក ស៊ីអ៊ីវ ទឹកម្ទេស សៀង សញ្ញា « ព្រាបស » ៣៧៧

២០.០២.៩៦ ប្រកាសលេខ ១០៣ ផក.ប្រក អនុញ្ញាតអោយលោក ជា សាន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរឧស្សាហកម្មតូចផលិតសំភារៈ ប្លាស្ទិច សញ្ញា SD « រូបភ្នំពីរ » ៣៧៧

២០.០២.៩៦ ប្រកាសលេខ ១០៤ ផក.ប្រក អនុញ្ញាតអោយលោក ហាន ណាំ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតទឹកត្រី សញ្ញា « ភ្នំស » ៣៧៨

២០.០២.៩៦ ប្រកាសលេខ ១០៥ ផក.ប្រក អនុញ្ញាតអោយលោក សាយ ឬន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ៣៧៩

២០.០២.៩៦ ប្រកាសលេខ ១០៦ ផក.ប្រក អនុញ្ញាតអោយលោក ប៊ុន ហ៊ុក ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតទឹកត្រី និង ទឹកស៊ីអ៊ីវ ៣៧៩

២០.០២.៩៦ ប្រកាសលេខ ១០៧ ផក.ប្រក អនុញ្ញាតអោយលោក ផេង អុក ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ២៤ សេះ ៣៨០

២០.០២.៩៦ ប្រកាសលេខ ១០៨ ផក.ប្រក អនុញ្ញាតអោយលោក គុយ ឈៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៨០ សេះ ៣៨០

២០.០២.៩៦ ប្រកាសលេខ ១០៩ ផក.ប្រក អនុញ្ញាតអោយលោក ឆេង មៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៤០ សេះ ៣៨១

២០.០២.៩៦ ប្រកាសលេខ ១១០ ផក.ប្រក អនុញ្ញាតអោយលោក លឹម ហៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៤០ សេះ ៣៨១

២០.០២.៩៦ ប្រកាសលេខ ១១១ ផក.ប្រក អនុញ្ញាតអោយលោក ភឹម ប៊ុនរ៉េម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ផ្ទេររោងម៉ាស៊ីនកិនស្រូវជូនលោក វ៉ាន់ នុត គ្រប់គ្រងវិញ ៣៨២

២០.០២.៩៦ ប្រកាសលេខ ១១២ ផក.ប្រក អនុញ្ញាតអោយលោក រស់ ផល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានរោងក្រឡឹងដែកផ្ទេរភារកិច្ច គ្រប់គ្រង ជូនអ្នកស្រី លឹម លី វិញ ៣៨២

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងពតិមាន

១—សេចក្តីសំរេច

០៩.០២.៩៦ សេចក្តីសំរេចលេខ ០៤២/៩៥ ពម.សសរ ស្តីពីការបង្កើត គណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និង ប្រគល់កិច្ចសន្យា (PEAC) ៣៨៣

២—ប្រកាស

០៩.០២.៩៦ ប្រកាសលេខ ០៤៧/៩៥ ពម.ប្រក អនុញ្ញាតិអោយលោក សេង សាយ បើកអាជីវកម្មរោងពុម្ពឈ្មោះ « សានហ៊ាក់» ៣៨៤

១២.០២.៩៦ ប្រកាសលេខ ០៤៨/៩៦ ពម.ប្រក ផ្អាកការចេញផ្សាយសារពតិមាន « សាធារណរដ្ឋ » ៣៨៦

១២.០២.៩៦ ប្រកាសលេខ ០៥៥/៩៦ ពម.ប្រក អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្តីឈ្មោះ « ពិភពលោកថ្មី» ៣៨៧

៤—ទីស្តីការក្រសួងកិច្ចការនារី

សេចក្តីប្រកាស

០៩.០២.៩៦	សេចក្តីប្រកាសលេខ ១៤៩ រកន ស្តីពីការតែងតាំងមន្ត្រីទទួលខុសត្រូវការងារលទ្ធកម្មសាធារណៈ នៃក្រសួងកិច្ចការនារី	៣៨៨

៥—ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

សារាចរណែនាំ

១៤.០២.៩៦	សារាចរណែនាំលេខ ០២ សកអ ស្តីពីការបើកប្រាក់ឧបត្ថម្ភមួយលើកជូនជនពិការវិលទៅមូលដ្ឋាន និង ជនពិការស្លាប់ដោយ របួសជម្ងឺ	៣៩១

៦—ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

១៥.០២.៩៦	ប្រកាសលេខ ០១៦ បទ អនុញ្ញាតអោយក្រុមហ៊ុន ម៉េង ស្រ៊ាង បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០២ គ្រឿង និង VHF ចំនួន ០៥ គ្រឿង	៣៩៣
១៥.០២.៩៦	ប្រកាសលេខ ០១៧ បទ.ប្រក អនុញ្ញាតអោយក្រុម ហ៊ុន ភែន អេសាអ៊ិនធើណេស្យូណាស ទូអិលធីឌី បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០៤ គ្រឿង	៣៩៤
១៥.០២.៩៦	ប្រកាសលេខ ០១៨ បទ.ប្រក អនុញ្ញាតអោយអង្គការ PACT បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០៥ គ្រឿង	៣៩៥
១៥.០២.៩៦	ប្រកាសលេខ ០១៩ បទ.ប្រក អនុញ្ញាតអោយអង្គការ AICF/USA CAMBODIA បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០៣ គ្រឿង និង VHF ចំនួន ០៥ គ្រឿង និងបន្ថែមចំនួន ០៤ គ្រឿង	៣៩៦

១៥.០២.៩៦ ប្រកាសលេខ ០២០ ប.ទ.ប្រក ស្តីពីការកំណត់បេឡាវេងជូនមន្ទីរ
ប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រុងព្រះសីហនុ ៣៩៧

៧—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

០៩.១២.៩៦ សេចក្តីសំរេចលេខ ១១៧ សសរ.មស.ក្រខ ស្តីពីការបែងចែកសិស្ស
និស្សិត ចំនួន ២៨ នាក់ ដែលទើបបញ្ចប់ការសិក្សាក្រៅប្រទេស ៣៩៩

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០២៩៦/០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក **មុត ខៀវ** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈ ស្មើអគ្គនាយក ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

* * *

II ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៤ អនក្រ . តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនជួយកសាងអាគារសិក្សានៅក្នុងសាលាបឋមសិក្សា ជាយ ឃុំជាយ ស្រុកបាភ្នំ ខេត្ត ព្រៃវែង ដូចមានរាយនាម ខាងក្រោម ÷

១- លោក **តាំង ពិន** ទឹកប្រាក់ ១០.០៧៣ ដុល្លារអាមេរិក

២-លោក **ពិន ឆាំង** ទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៥ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស អោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា

ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ចនៃរាជរដ្ឋាភិបាល

–តាមសំណើចាំបាច់របស់ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ច

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងអស់លោកដូចមានរាយនាមខាងក្រោមអោយទទួលភារកិច្ចនៅអគ្គលេខាធិការដ្ឋានអធិការកិច្ចនៃរាជរដ្ឋាភិបាល ÷

១– លោក **ខឹម ជាវសោភ័ណ** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអធិការកិច្ចនៃរាជរដ្ឋាភិបាល ។

២– លោក **សុខ គុន** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអធិការកិច្ចនៃរាជរដ្ឋាភិបាល ។

៣– លោក **គ្រួច ម៉ុនលី** ជានាយអធិការទទួលបន្ទុកអធិការកិច្ច

៤– លោក **គីម សាន** ជានាយអធិការទទួលបន្ទុកស្រាវជ្រាវកិច្ចការរាជរដ្ឋាភិបាលប្រគល់អោយ ។

៥– លោក **គង់ កម្ពុជបុត្រ** ជានាយអធិការទទួលបន្ទុកតាមដានការអនុវត្តន៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ២ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ច សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង អស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវទទួលអនុវត្ត តាមអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III ការងារបណ្ដាក្រសួង

១–ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០១១ ប្រក

ស្ដីពីការបង្កើតគណៈកម្មាធិការកំណត់បូរលេកូណៈ

សម្បត្តិវាយតម្លៃនិង ប្រគល់ភារកិច្ចសន្យារបស់

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាល

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការ កែសំរួលសមាសភាពនៃរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបាន ប្រកាសអោយប្រើជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី ២០ខែកក្កដា ឆ្នាំ ១៩៩៤

– បានឃើញអនុក្រឹត្យលេខ ៦០ អនក្របក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ រាជរដ្ឋាភិបាល ស្ដីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

– បានឃើញសារាចរណែនាំលេខ ០០៦ សណន ស.ហ.វ.សក ចុះថ្ងៃទី ១៤ ខែ

វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-យោងតាមការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ១ : បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **នាយ ចន** អនុរដ្ឋលេខាធិការ ជាប្រធាន

២-លោក **ប្រាក់ ឡេង** ប្រធានមន្ទីរ ជាសមាជិក

៣-លោក **សាម ប៊ុនហេង** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ជាសមាជិក

៤-លោក **នាយ ទុន** អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ជាសមាជិក

៥-លោក **ម៉ូយ ខិន** ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការ

គណៈកម្មាធិការនេះមានភារកិច្ចទទួលខុសត្រូវ ក្នុងការកំណត់បុរេលក្ខណៈសម្បត្តិការ វាយតំលៃលើសំណើដេញថ្លៃ និង សំណើទីប្រឹក្សា ព្រមទាំងផ្តល់អនុសាសន៍ ប្រគល់កិច្ចសន្យា ។

ប្រការ ២ : បង្កើតអង្គភាពលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមាន សមាសភាពដូចខាងក្រោម ÷

១-លោក **ម៉ូយ ខិន** ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ ជាប្រធាន

២-លោក **ទន់ ពៅរ៉ូ** អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានលទ្ធកម្ម សាធារណៈជាអនុប្រធាន ។

៣-លោក **ឡុង ប៊ុនធី** មន្ត្រីការិយាល័យរដ្ឋបាល ជាសមាជិក

៤-លោក **លី សារុន** មន្ត្រីការិយាល័យរដ្ឋបាល ជាសមាជិក

៥-លោក **តូច ទារ៉ាម៉ូរ** មន្ត្រីការិយាល័យរដ្ឋបាល ជាសមាជិក

អង្គភាពលទ្ធកម្មនេះមានភារកិច្ចដូចបានចែងក្នុងផ្នែកទី ២៣ នៃប្រកាសលេខ ៣១៩ សហវ មប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តវិធាននិងបទបញ្ញត្តិ ក្នុងការគ្រប់គ្រង លទ្ធកម្មសាធារណៈ ។

ប្រការ៣ : មន្ត្រីរាជការដែលមានឈ្មោះក្នុង គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា និង អង្គភាពលទ្ធកម្ម ខាងលើត្រូវបំពេញភារកិច្ច បន្ថែមលើតួនាទីចាស់ដែលមានពីមុនមក ។

ប្រការ ៤ : គណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា និងអង្គភាពលទ្ធកម្មសាធារណៈ ត្រូវបំពេញការងារលទ្ធកម្មសាធារណៈ របស់ក្រសួង ផ្អែកតាមគោលច្បាប់ជាធរមានអោយទទួលបានលទ្ធផលល្អប្រសើរ ។

ប្រការ ៥ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ប្រធាននាយកដ្ឋានបុគ្គលិក អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចប្រការ ១ និង ប្រការ ២ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០១២ សហវ លស ប្រក
ស្តីពីការបង្កើតគណៈកម្មាធិការ បែងចែកតាមប្រភេទ
និង ចំណាត់ថ្នាក់ អ្នកទទួលការសាងសង់

* * * * * * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាព នៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបាន ប្រកាសអោយប្រើជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ

កក្កដា ឆ្នាំ ១៩៩៤

–បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ។

–បានឃើញប្រកាសលេខ ៣៦៣ សហវ លស ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់

–បានឃើញការចាំបាច់របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មាធិការបែងចែកតាមប្រភេទ និង ចំណាត់ថ្នាក់ អ្នកទទួលការសាងសង់ដូចមានសមាសភាពខាងក្រោម ÷

១–លោក **ឆាយ ធុន** អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ជាប្រធាន

២–លោក **យិន ម៉ុណ្ណារ៉ា** តំណាងក្រសួងសាធារណៈការនិងដឹកជញ្ជូន សមាជិក

៣–លោក **ចាន់ ជឹងគីង** តំណាងសភាពាណិជ្ជកម្ម សមាជិក

៤–លោក **ខួន មាស** ប្រធានការិយាល័យពិគ្រោះយោបល់ លេខាធិការ

ប្រការ ២ : គណៈកម្មាធិការនេះ បង្កើតឡើង ដើម្បីធ្វើការវាយតំលៃលើការបែងចែកតាមប្រភេទ និង ចំណាត់ថ្នាក់អ្នកទទួលការសាងសង់ ស្របទៅតាមគោលច្បាប់ជាធរមាន ។

ប្រការ ៣ : គណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ :លោកនាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ លោកប្រធាន នាយកដ្ឋានលទ្ធកម្មសាធារណៈ នឹង សាម៉ីខ្លួនមានភារកិច្ចអនុវត្តតាមសេចក្តីប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រកាសលេខ ០១៣ ប្រក.សហវ.ថ

ស្តីពីការណែនាំអនុវត្តន៍អនុក្រឹត្យរបស់រាជរដ្ឋាភិបាល

លេខ ០៧ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦

ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង

* * *

យោលទៅលើខ្លឹមសារនៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៧ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦ ស្តីពីចំណាយគុណប្រយោជន៍ខេត្ត ក្រុង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើ ការណែនាំអនុវត្តជាក់ស្តែងដូចតទៅ ÷

១–ខេត្ត ក្រុងនីមួយៗ ត្រូវកសាងជាបន្ទាន់នូវគំរោងចំណូល ចំណាយតាមខ្លឹមសារ មាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦ ដោយចែកជាត្រីមាសនីមួយៗ ហើយផ្ញើមកសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអោយបានមុនថ្ងៃ ២០ ខែ កុម្ភៈ ឆ្នាំ ១៩៨៦ ។

គំរោងចំណូលត្រូវភ្ជាប់មកលិខិតយុត្តិការនានា ដូចជាកិច្ចសន្យាបង់ចំណូល សេចក្តីបញ្ជាក់អំពីមូលហេតុនៃលទ្ធភាពចំណូលជាក់ស្តែង ។ ល ។ រីឯគំរោងចំណាយក៏ត្រូវមានគំរោងលំអិតតាម មុខសញ្ញានិមួយៗ និងសេចក្តីបញ្ជាក់អំពីភាពចាំបាច់ដែលត្រូវចំណាយដែរ ។

២–ក្នុងពេលពិនិត្យសំរេចលើគំរោងចំណូលចំណាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចដកចេញ ឬ បំពេញបន្ថែមនូវមុខសញ្ញាចំណូលចំណាយទាំងឡាយក្នុងករណីចាំបាច់ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសំរេចផ្តល់ឧបត្ថម្ភឥណទានជូនខេត្ត ក្រុង នៅក្របខ័ណ្ឌឥណទានជំពូក ១២ ដែលបានគ្រោងទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៨៦ ។

៣–ក្រោយពេលមានការឯកភាពយល់ព្រមលើគំរោងចំណូលចំណាយ ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរួចហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើប្រកាស ផ្ទេរឥណទានជំពូក ១២ ជូនខេត្ត ក្រុង សំរាប់អនុវត្តកម្មវិធីចំណាយក្នុងត្រីមាសទី១ ។

នៅចុងត្រីមាសនិមួយៗខេត្ត ក្រុងចាំបាច់ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលចំណាយ តាមខ្លឹមសារដូចមានក្នុងមាត្រា ៥ នៃអនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលជូនក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធ្វើជាមូលដ្ឋានក្នុងការ ពិនិត្យផ្តល់ឧបត្ថម្ភឥណទានជូនខេត្ត ក្រុងសំរាប់អនុវត្តក្នុងត្រីមាសក្រោយទៀត ។ ចំពោះរបាយការណ៍ចំណូលត្រូវមានបញ្ជាក់ទទួលស្គាល់របស់រតនាគារផង ។

៤–ការចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ត្រូវអនុវត្តទៅតាមកម្មវិធីចំណាយដែលបាន ការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង ប្រតិបត្តិតាមនីតិវិធី និង បទបញ្ញត្តិទាំងឡាយនៃការអនុវត្តន៍ថវិកាទូទៅរបស់រដ្ឋ ។

៥–ក្នុងការអនុវត្តន៍ប្រកាសណែនាំនេះ បើមានជួបបញ្ហាណាដែលជាការលំបាកនោះ សូមមកពិភាក្សាដោះស្រាយជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាបន្ទាន់

ប្រកាសណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០១៤ ប្រក.សហវ.ថ

ស្តីពីការប្រគល់ភារកិច្ចចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៨ អនក្រ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០១ ប្រ.សហវ.ថ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីចំណាត់ថ្នាក់ ចំណូល និង ចំណាយ តាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ អនុ ខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២២ ប្រ.សហវ.ថ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ លេខ ០០៣ ប្រ.សហវ.ថ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ និងលេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការកែប្រែចំណាត់ថ្នាក់ចំណូល ចំណាយ ថវិកាទូទៅរបស់រដ្ឋ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ចំណូលជាប្រចាំ និង ជាមូលធននៃថវិកាទូទៅរបស់រដ្ឋ ដែលបានគ្រោងទុក និង អនុញ្ញាតដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ និង ដែលបាន បែងចែកដោយរាជរដ្ឋាភិបាលតាមអនុក្រឹត្យលេខ ០៨ អនក្រ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ត្រូវបានប្រគល់ភារកិច្ចជូនក្រសួងស្ថាប័ន ដែលមានប្រភព ចំណូលដោយអនុលោមតាមតារាងដែលជូនភ្ជាប់និងប្រកាសនេះ ។

ប្រការ ២ : រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុង ជាអ្នកទទួលបន្ទុកប្រមូលចំណូលអោយបានតាមគំរោង ឬ លើសគំរោង ដើម្បីជាគុណប្រយោជន៍ដល់ថវិកាទូទៅរបស់រដ្ឋ ។

ប្រការ ៣ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៨៦ ។

ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

២— ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាសលេខ ៨៨ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុង ស៊ីផាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណលេខ ២១២៤២៣ ក.ច ចុះថ្ងៃទី ០៥–៧–៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិស្លង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម បើក ដំណើរការរោងម៉ាស៊ីនផលិតទឹកកក ដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី ប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៨៩ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនផលិតទឹកកកដើម ដែលមានលោក **ហាក់ ប៊ុនឈឹម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៤៦៦០០២ ក.ច ចុះថ្ងៃទី

០៨_៩_៨០ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម បើកដំណើរការផលិតកម្មនៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩០ ផក.ប្រក. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី ប្រាក់ សុខុម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៧៣០៤ ក.ណ ចុះថ្ងៃទី ០១_០១_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកថ្មី ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤សេះនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី ប្រាក់ សុខុម ត្រូវបន្តដំណើរការផលិតកម្ម_ អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះ ពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩១ ផក.ប្រក.ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក ចាន ខេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៦៨៩៣ ភ.ព ចុះថ្ងៃទី ០៩_៥_៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៨ ផ្លូវលេខ ២៥៥ ក្រុមទី ១៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរសិប្បកម្មផលិតស្រាស សញ្ញា " ផ្កាឈូក " នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ចាង ខេង** ត្រូវបានអនុញ្ញាតអោយផលិត នូវផលិតផលស្រាស សញ្ញា "ផ្កាត្នោត " ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្នុងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩២ ឧក.ប្រក.ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **មង់ សេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៥២៨៧ ក.ធ ចុះថ្ងៃទី ២២_១១_៨៦ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ១៣ ភូមិកំពង់ក្របៅ ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធសញ្ញា " សេះស " នៅក្នុង ទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **មង់ សេង** ត្រូវបានអនុញ្ញាតអោយផលិត នូវមុខផលិតផលទឹកបរិសុទ្ធសញ្ញា "សេះស " ស្របតាមគំរូនិងផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី ប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩៣ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ចេង ស្រួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤១៨៤៣ ភ.ព ចុះថ្ងៃទី ១៨_០១_៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១១២ ផ្លូវលេខ ១៦៣ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការឡ

ផលិតឥដ្ឋក្បឿង នៅក្នុងទីតាំងភូមិដំបូកកោះ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរខេត្ត កំពង់ឆ្នាំង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩៤ ឧក.ប្រក.ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហួយ អ៊ីង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ២៤៩២៦០ ក.ណ ចុះថ្ងៃទី ០២_០៤_៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិ កំពង់កុង ឃុំកំពង់កុង ស្រុកកោះធំ ខេត្ត កណ្តាល បើកដំណើរការរោងម៉ាស៊ីន ផលិតទឹកកកដើម នៅក្នុងទីតាំងភូមិលេខ ២ ឃុំពោធិបាន ស្រុក កោះធំខេត្ត កណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៩៥ ឧក.ប្រក.ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អ៊ុច សុធា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ២៩៤០៦១ ភ.ព ចុះថ្ងៃទី ១២_០២_៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៤៥២ សេអ៊ី០ ផ្លូវលេខ ៣១០ ក្រុមទី ៦០ សង្កាត់បឹងកេងកងទី ៣ ខ័ណ្ឌ ចំការមនរាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ នៅក្នុង ទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៩៦ ឧក.ប្រក.ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស៊ុំ ឈី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៥៧៦៩ ភ.ព ចុះថ្ងៃទី ២២–៤–៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១២៨ អឺ០ ផ្លូវលេខ ១៩ សង្កាត់ជ័យ ជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្ម ផលិតទឹកស៊ីអ៊ីវ ទឹកម្ទេសសៀង សញ្ញា " ព្រាបស " នៅក្នុងទីតាំងផ្លូវជាតិលេខ ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : អ្នកស្រី **ស៊ុំ ឈី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកស៊ីអ៊ីវសញ្ញា "ព្រាបស " រូបព្រាបស "រូបក្បាលមាន់ " រូបផ្សិត១ " និងទឹកម្ទេសសៀង សញ្ញា "ព្រាបស " រូបម្ទេសប្លោក និង ម្ទេសវែង " ស្របតាមគំរូនិងផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៣ ឧក.ប្រក. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូច ផលិតសំភារៈប្លាស្ទិក សញ្ញា SD " រូបភ្នំពីរ " ដែលមានលោក **ជា សាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤៦៣៣៣២ ភ.ព ចុះថ្ងៃទី ២៩–៣–៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧៣ អឺ០ ផ្លូវលេខ ១៣៦ សង្កាត់ផ្សារថ្មីទី ៣ ខ័ណ្ឌដូនពេញ រាជធានី

ភ្នំពេញបើកដំណើរការផលិតកម្ម នៅក្នុងទីតាំងភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ជា សាន** ត្រូវចាប់ផ្តើមរៀបចំឧស្សាហកម្មតូចរបស់ខ្លួនអោយរួចស្រេចជាស្ថាពរ ក្នុង រយៈពេល ៣ ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : លោក **ជា សាន** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ចង់យួរ , បាវ និង ខ្សែអំពីប្លាស្ទិកសញ្ញា SD " រូបភ្នំពីរ " ស្របតាមគំរូ និង ផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពល្អ មិនធានាក្នុងការប្រើប្រាស់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៤ ឧក.ប្រក. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហាន ណាំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៧០៧៤ កព ចុះថ្ងៃទី ០១_០២_៨៨ អាស័យដ្ឋានបច្ចុប្បន្នភូមិកំពង់ត្រាចទី ១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត បើកដំណើរការសិប្បកម្មផលិតទឹកត្រីសញ្ញា " ភ្នំស " នៅក្នុងទីតាំងដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ហាន ណាំ** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ទឹកត្រីសញ្ញា "ភ្នំស" "រូបត្រីពីរ" ស្របតាមគំរូ និងផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ១០៥ ឧក.ប្រក.ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនផលិតទឹកកកដើម ដែលមានលោក **សាយ ប្អូន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៧១៩៦ ក.ព ចុះថ្ងៃទី ១៧-០១-៩២ ជាប្រធានទីលំនៅស្ថានបច្ចុប្បន្ន ភូមិភ្នំត្រែល ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត បើកដំណើរការផលិតកម្ម នៅក្នុងទីតាំងភូមិ ពោធិ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៦ ឧក.ប្រក. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ិន ហ៊ុក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៩១០៤ ក.ព ចុះថ្ងៃទី ២៨-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៩ អឺ១ ហ្សេត ផ្លូវលេខ ១៦៤ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតទឹកត្រី និង ទឹកស៊ីអ៊ីវ នៅក្នុងទីតាំងភូមិ ខ្វា សង្កាត់ ដង្កោ ខ័ណ្ឌដង្កោរាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ម៉ិន ហ៊ុក** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ទឹកត្រីកំពតសញ្ញា "រូបត្រីខ្វា" និងទឹកស៊ីអ៊ីវសញ្ញា "រូបរមាស" និង "រូបអូដ្ឋ" ស្របតាមគំរូ និងផ្លាកសញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ១០៧ ឧក.ប្រក.ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឆេង អុក** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៨៤២៥ ក.ស្ត ចុះថ្ងៃទី ០៥_១១_៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិស្ពានតោ ឃុំរលាំងគ្រើល ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤សេះនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឆេង អុក** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៨ ឧក.ប្រក. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **កុយ ឈឿង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣៨៦៣៨ ក.ស្ត. ចុះថ្ងៃទី ០៦_៦_៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិទួលព្រីង ឃុំពេជមន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០សេះ នៅក្នុងទីតាំងក្រុមទី ៣ ភូមិ អង្គមេត្រី ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : លោក **កុយ ឈឿង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្មលើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១០៩ ឥក.ប្រក.ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **សេខ មៅ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៥៣០០ ក.ស្ក. ចុះថ្ងៃទី ១០_៥_៩៣ អាស័យដ្ឋានបច្ចុប្បន្នភូមិស្ពានតោ ឃុំរលាំងគ្រើល ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **សេខ មៅ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្មលើទីតាំង ដូចបានកំណត់ក្នុងប្ញង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១១០ ឥក.ប្រក. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **លឹម ហឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៨៤១៤ ក.ស្ក. ចុះថ្ងៃទី ០៥_១១_៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិស្ពានតោ ឃុំរលាំងគ្រើល ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០សេះ នៅក្នុងទីតាំង ភូមិ អង្គមេត្រី ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : លោក **លឹម ហឿន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្មលើទីតាំងដូចបាន កំណត់ក្នុងប្ញង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១១១ ផក. ប្រក. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **គីម ម៉ុនរ៉េម** ជាប្រធានរោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំងនៅ ផ្ទះលេខ ២០៦ ក្រុមទី ១៧ ភូមិបវេលទី ១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់គ្រង ជូនលោក **ទ័រន់ នុត** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **ទ័រន់ នុត** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៧៨៥៣៥ ភ.ព. ចុះថ្ងៃទី ១២-១២-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៦៩ អឺ០ ក្រុមទី ៤ ផ្លូវ ១១០ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំង ដូចមានចែងក្នុង ប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៤ : ប្រកាសលេខ ១៩១ ផក.ប្រក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍ ។

* * *

ប្រកាសលេខ ១១២ ផក.ប្រក.ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សេ ផល** ជាម្ចាស់រោងជាងគ្រឿងដែក ដែលមានទីតាំងនៅ ផ្ទះលេខ ៦ អឺ០ ផ្លូវលេខ ២១៧ សង្កាត់ផ្សារថ្មីទី ២ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ផ្ទេរភារកិច្ចគ្រប់គ្រងជូនអ្នកស្រី **លឹម លី** វិញ ។

ប្រការ ២ : ទទួលស្គាល់អ្នកស្រី **លឹម លី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៥០៦៧ ភ.ព. ចុះថ្ងៃទី ១៧-១២-៩០ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦ អឺ០ ផ្លូវ ២១៧ សង្កាត់ផ្សារថ្មីទី ២ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ជាម្ចាស់រោងជាងគ្រឿងដែក ដែលមានទីតាំងអាស័យដ្ឋានដូចខាងលើ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ ៤ : ប្រកាសលេខ ២៣២ ផក.ប្រក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ត្រូវបានចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

* * *

៣— ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១—សេចក្ដីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ០៤២/៩៦ ពម.សសរ

ស្ដីពីការបង្កើតគណៈកម្មាធិការ កំណត់មុនលក្ខណៈសម្បត្តិ

វាយតំលៃនិងប្រគល់កិច្ចសន្យា (PEAC)

* * *

- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្ដីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៦ សណន.សហវ.លស ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការអនុវត្តនីតិវិធាន និងបទបញ្ញត្តិ ក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញសេចក្ដីប្រកាសលេខ ៣៦៣ សហវ.លស.ប្រក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់

-បានឃើញសេចក្តីប្រកាសលេខ ៣១៩ កហមវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តវិធានការនិងបទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា (PEAC)

១-ឯកឧត្តម **អ៊ុំ ឆាស៊ាម** អនុរដ្ឋលេខាធិការ ប្រធាន

២-លោក **សេង ម៉ាឈីស** អគ្គនាយករង សមាជិក

៣-លោក **សែន សំណាង** អគ្គាធិការរង សមាជិក

៤-លោក **សេង នីន** ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការ

៥- សាមីអង្គភាពពាក់ព័ន្ធ ចូលរួមស្រាយបំភ្លឺ

ប្រការ ២ : ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមដីការសំរេច ។

ប្រការ ៣ : ដីកាសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អឿង មូលី

* * *

២—ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៤៧/៩៦ ពម.ប្រក

អនុញ្ញាតអោយលោក សេង សាយ

បើកអាជីវកម្មរោងពុម្ពឈ្មោះ « សាន ចាក់ »

រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ...

-យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១.២២៤.៩៤ ព.ម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ

-យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ "**សាន ម៉ាក់**" របស់លោក **សេខ សាយ** ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **សេខ សាយ** ស្ថិតនៅផ្ទះលេខ ២៩ ផ្លូវ ៤១០ ក្រុមទី ០៤ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ "**សាន ម៉ាក់**" ដែលមានទីតាំងស្ថិតនៅលំនៅដ្ឋានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ-សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៤៩/៩៦ ពម.ប្រក

ផ្អាកការចេញផ្សាយសារពត៌មាន

« **សាធារណរដ្ឋ** »

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨៩៥–០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ២៦០/៩៥ ពមប្រក. ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥ សំរេចអនុញ្ញាតអោយបោះពុម្ពផ្សាយកាសែត "សាធារណរដ្ឋ " ដែលមានលោក **លឹម រតនា** ជាចាងហ្វាងការផ្សាយ ។

សំរេច

ប្រការ ១ : ផ្អាកការចេញផ្សាយសារពត៌មាន " សាធារណរដ្ឋ " ក្នុងរយៈពេល ៣០ថ្ងៃគិតចាប់ពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។ ផុតកំណត់នេះ ការចេញផ្សាយឡើងវិញជាសមត្ថកិច្ចរបស់តុលាការ ។

ប្រការ ២ : អគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន ប្រធានមន្ទីរពត៌មានរាជធានីអាជ្ញាធរពាក់ព័ន្ធ និងលោក **លឹម រតនា** ត្រូវអនុវត្តអោយបានសំរេចតាមសេចក្តីនៃប្រកាស នេះ ។

ប្រការ ៣ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៥៥/៩៦ ពម.ប្រក

អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្ដី

ឈ្មោះ « ពិភពលោកថ្មី»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៣មាត្រាទី៤១ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ។
- បានឃើញសំណើសុំរបស់លោកស្រី គីម ហឿង ចាងហ្វាងទស្សនាវដ្ដីឈ្មោះ «ពិភពលោកថ្មី ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្ដីឈ្មោះ « ពិភពលោកថ្មី » ដោយមានលោកស្រី **គីម ហឿង** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ១៦៤៥ សេ ផ្លូវលេខ ៥ ក្រុម១២ សង្កាត់ឫស្សី កែវ ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្ដូរនូវចំណុចណាមួយ ក្នុងអត្តសញ្ញាណប័ណ្ណនៃទស្សនាវដ្ដីរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ១០ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្ដីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែតឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុង វិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបានសមស្រប តាមទំនៀមទំលាប់ ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ទស្សនាវដ្ដីចំនួន០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្ដីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : លោកស្រី **គីម ហៀង** ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

៤—ទីស្តីការក្រសួងកិច្ចការនារី

សេចក្តីប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សេចក្តីប្រកាសលេខ : ១៤៩ អកន
ស្តីពីការតែងតាំងមន្ត្រីទទួលខុសត្រូវការងារ
លទ្ធកម្មសាធារណៈ នៃក្រសួងកិច្ចការនារី

រដ្ឋលេខាធិការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ សន ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥
- យោងអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ក្នុងមាត្រា ២១–២២

- យោងសេចក្តីប្រកាសលេខ ៣១៩ សហវប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ក្នុងទំព័រលេខ ១៧-១៨-១៩-២០
- យោងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុលេខ ០០៦ សណន. សហវ.លស ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និង បទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្ម សាធារណៈ ។

សម្រេច

ប្រការ១ : បង្កើតអង្គភាពលទ្ធកម្មមួយមានឈ្មោះថា" អង្គភាពលទ្ធកម្មក្រសួងកិច្ចការនារី" ដែលមានទីតាំង នៅក្នុងនាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងកិច្ចការនារី ។

ប្រការ២ : អង្គភាពលទ្ធកម្មក្រសួងកិច្ចការនារីមានក្រុមការងារបីផ្នែក ទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការ ÷

ក- អង្គភាពលទ្ធកម្ម

ខ- អង្គភាពលទ្ធកម្មត្រួតពិនិត្យលទ្ធកម្ម

គ- គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា ។

ប្រការ៣ : ចាត់តាំងលោកជំទាវ **ស៊ុន វួចឈាន** អនុរដ្ឋលេខាធិការ ជាអ្នកទទួលខុសត្រូវរួមលើអង្គភាព លទ្ធកម្មក្រសួងកិច្ចការនារី ។

ប្រការ៤ : ចាត់តាំងសមាសភាព និង តួនាទីរបស់ " អង្គភាពលទ្ធកម្ម " (PU) ÷

១-លោក	**យស សារឿន**	នាយក នាយកដ្ឋានរដ្ឋបាល	ប្រធាន
២-អ្នកស្រី	**សុខ ចំន្ទធីរ៉ា**	នាយកដ្ឋានរដ្ឋបាល	សមាជិក
៣-លោក	**ម៉ី ហ៊ឹល**	នាយកដ្ឋានផែនការ	សមាជិក
៤-លោក	**យឹម សាម៉េន**	នាយកដ្ឋានហិរញ្ញកិច្ច	សមាជិក

អង្គភាពនេះមានតួនាទី ÷

ក-រៀបចំឯកសារចាំបាច់" រួមមានទាំងឯកសារដេញថ្លៃ ដោយប្រកួតប្រជែង" សំរាប់ចំលង ការលទ្ធកម្មណាមួយ ដោយធ្វើការពិគ្រោះ ឬ ដោយមានការឧបត្ថម្ភពីអង្គភាពពាក់ព័ន្ធ ផ្សេងទៀតនៅក្នុងក្រសួងកិច្ចការនារី ។

ខ-រៀបចំបោះពុម្ពផ្សាយសេចក្តីអញ្ជើញអោយចូលរួមដេញ ថ្លៃនៅក្នុងសារពត៌មានជាតិ ឬ បរ ទេស និង ផ្ញើលិខិតសាកសួរថ្លៃទៅអ្នកផ្គត់ផ្គង់ការ ។

គ-បញ្ជូនឯកសារដេញថ្លៃ ទៅអោយភាគីដែលចង់បានឯកសារទាំងនោះ ។

ឃ-ទទួលសំណើដេញថ្លៃ ឬ តារាងថ្លៃពីអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការដែលចូលរួមព្រមទាំងធ្វើការពិនិត្យភាពសមស្របរបស់សំណើដេញថ្លៃ ។

ង-បញ្ជូនការងារលទ្ធកម្ម ដែលចាំបាច់ទៅនាយកដ្ឋានលទ្ធកម្មសាធារណៈ ហើយរៀបចំ និង បញ្ជូនទំរង់របាយការណ៍ដេញថ្លៃ ឬ ទំរង់របាយការណ៍លទ្ធកម្ម ។

ច-ផ្ញើលិខិតអំពីការទទួលសំណើទៅអ្នកដេញថ្លៃឈ្នះ ព្រមទាំងរៀបចំចុះហត្ថលេខាលើកិច្ចសន្យាដែលបានអនុម័តរួចហើយ ។

ប្រការ៥ : ចាត់តាំងសមាសភាព និង តួនាទីរបស់" អង្គភាពលទ្ធកម្មត្រួតពិនិត្យលទ្ធកម្ម" (AUDIT) ÷

១-លោក **ខាំ ពីន** នាយកខុទ្ទកាល័យ ប្រធាន

២-លោកស្រី **អេន សំអាន** អគ្គនាយកកម្មវិធី សមាជិក

៣-លោកស្រី **គួ លីចេង** អគ្គនាយកហិរញ្ញកិច្ច និង ផែនការ សមាជិក

អង្គភាពនេះមានតួនាទី ÷

ក-ធ្វើការត្រួតពិនិត្យបញ្ជី ឬ មានតួនាទីពាក់ព័ន្ធផ្សេងទៀតក្នុងការចំលងការ ឬ សកម្មភាព ផ្សេងៗ នៅក្នុងក្រសួង ។

ខ-ត្រូវមានភារកិច្ចត្រួតពិនិត្យលើលិខិតចំលងការលទ្ធកម្ម ដែលបានបញ្ចប់រួចហើយ ដើម្បីកំណត់បញ្ជាក់ថា តើគេបានធ្វើត្រឹមត្រូវតាមល័ក្ខខ័ណ្ឌ នៃ កិច្ចសន្យា ឬ យ៉ាងណា ។

គ-ត្រូវរាយការណ៍ពីគំហើញទាំងឡាយទៅប្រធានស្ថាប័ន បញ្ជូនលិខិតចំលងជការនៃរបាយការណ៍នេះទៅនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីជាពត៌មាន និង ទង្វើសមស្របណាមួយ ។

ឃ-ផ្តល់នូវអនុសាសន៍អោយផ្អាកការទូទាត់ចំពោះកិច្ចសន្យាដោយឡែកណាមួយប្រសិនបើការ ទូទាត់ចប់សព្វគ្រប់ ឬ មួយក៏បញ្ឈប់ការទូទាត់ទាំងស្រុង បើមានរកឃើញការរំលោភលើកិច្ចសន្យា ។

ប្រការ៦ : ចាត់តាំងសមាសភាព និង តួនាទីរបស់" គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតំលៃ និង ប្រគល់កិច្ចសន្យា" (PEAC) ÷

១–លោកជំទាវ ស៊ីង ទួចឈាន អនុរដ្ឋលេខាធិការ ជាប្រធាន

២–លោក ខឹម សោភ័ណ នាយក នាយកដ្ឋានផែនការ សមាជិក

៣–លោក ឈឿង ហេង នាយក នាយកដ្ឋានហិរញ្ញកិច្ច សមាជិក

៤–លោក យស សាខន ប្រធានអង្គភាពលទ្ធកម្ម លេខាធិការ

គណៈកម្មាធិការនេះមានតួនាទី :

–ទទួលខុសត្រូវការកំណត់ បុរេលក្ខណៈសម្បត្តិការដេញថ្លៃ ការវាយតំលៃលើ សំណើដេញថ្លៃ និង សំណើទីប្រឹក្សា ព្រមទាំងផ្តល់អនុសាសន៍ប្រគល់កិច្ចសន្យា ។

ប្រការ៧ : សេចក្តីប្រកាស សំរេចលេខ ១០២៣ រកន ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៥ ត្រូវបានចាត់ទុកជានិរាករណ៍ ។

ប្រការ៨ : សមាសភាពដែលបានចែងក្នុងប្រការ (៣)–(៤)–(៥)–(៦) ត្រូវអនុវត្តតាមសេចក្តីប្រកាស នេះអោយមានប្រសិទ្ធភាពចាប់ពី ថ្ងៃទីហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គៀត សុគន្ធ

* * *

៥–ទីស្តីការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៨៦

សារាចរណែនាំលេខ ០២ សក

ស្តីពីការបើកប្រាក់ឧបត្ថម្ភមួយលើកជូនជនពិការ

វិលទៅមូលដ្ឋាន និង ជនពិការស្លាប់ដោយរបួសចាស់

ដើម្បីអនុវត្តសេចក្តីសំរេចលេខ ២០ សសរ ចុះថ្ងៃទី ៣០–០១–១៩៨១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយចំពោះជនពលីពិការ និង សេចក្តីណែនាំអន្តរក្រសួងលេខ ០៩ សណន. ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៨១ ស្តីពីការអនុវត្តន៍សេចក្តីសំរេចលេខ ២០

សសរ ចុះថ្ងៃទី ៣០-០១-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីអោយបានល្អ និង ច្បាស់លាស់ ជៀសវាងការភាន់ច្រឡំ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន សូមធ្វើការណែនាំគ្រប់អធិការដ្ឋានសង្គមកិច្ចការងារ និង អតីតយុទ្ធជនខេត្ត-ក្រុងនូវខ្លឹមសារមួយចំនួនដូចតទៅ ÷

១-ការបើកប្រាក់ឧបត្ថម្ភមួយលើកជូនជនពិការ វិលទៅរស់នៅមូលដ្ឋានតាម កំណត់ដូចមានចែងក្នុង កថាខ័ណ្ឌ" ឃ" ក្នុងចំណុច ១៣ ប្រការ ៧ នៃសេចក្ដីសំរេចលេខ ២០ សសរ ចុះថ្ងៃទី ៣០-០១-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយចំពោះជនពលីពិការ គឺអនុវត្តចំពោះតែជនពិការដែលចេញពីមណ្ឌលចិញ្ចឹមក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនតែប៉ុណ្ណោះ ។ បច្ចុប្បន្នមណ្ឌលទាំងនេះបានប្រែក្លាយទៅជាមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការ ឬ មណ្ឌលស្ដារលទ្ធភាពពលកម្ម ជនពិការហើយ ដូច្នេះការឧបត្ថម្ភតាមចំណុចខាងលើនេះមិនមានទៀតទេ ។

២-ករណីជនពិការដែលទទួលមរណៈភាពដោយរបួសសើរើ ហើយស្នើក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនទទួលស្គាល់ជាជនពលី និង ផ្ដល់របបគោលនយោបាយជូនគ្រួសារត្រូវមានសំណុំលិខិតដូចចែង ក្នុងចំណុច" ក" និង" ខ" ខាងក្រោមនេះ ÷

ក-ករណីមរណៈភាពនៅមន្ទីរពេទ្យ ត្រូវមានលិខិតបញ្ជាក់ពីប្រធានមន្ទីរពេទ្យខេត្ត-ក្រុងដែលធានាអះ អាងថាពិតជាមរណៈភាពដោយរបួសសើរើប្រាកដមែន ។

ខ-ករណីមរណៈភាពនៅផ្ទះ ត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់ពីគណៈកម្មការកោសល្យវិច័យវេជ្ជសាស្ត្ររបស់សុខាភិបាលខេត្ត-ក្រុង ។

៣-ចំពោះរបបគោលនយោបាយសំរាប់ជនពិការប្រភេទ" ក" ដែលស្លាប់ដោយរបួសសើរើពិតប្រាកដ ហើយត្រូវផ្ទេរមកទទួលរបបពលីវិញ តាមចំណុចទី ៥ ប្រការ ៧ នៃសេចក្ដីសំរេចលេខ ២០ សសរ ចុះ ថ្ងៃទី ៣០-០១-១៩៩១ នោះគឺអនុវត្តតាមចំណុច II នៃប្រការ ២ របស់សេចក្ដីសំរេចលេខ ២០ សសរនេះ ។

អាស្រ័យហេតុនេះ សូមគ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជនខេត្ត-ក្រុងអនុវត្តអោយបានត្រឹមត្រូវតាមខ្លឹមសារសារាចរណែនាំនេះ ។

ហត្ថលេខា និង ត្រា

ស៊ុយ សែម

* * *

៦—ទីស្ដីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ០២ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ០១៦ មឧ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥–៣–៨៧ ស្ដីពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF & VHF របស់ក្រុមហ៊ុន **ម៉េង ស្រ៊ាង** លេខ ០៤១២១០២ និង ០៤២២១០២ ចុះថ្ងៃទី ២៤–០១–៩៦ ។
- ប្រកាសលេខ ២១១ និង ២១២ បទប្រកទអ ចុះថ្ងៃទី ១៤–១២–៩៤ ។
- សេចក្ដីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ១១–១០–៩៥ ។

សំរេច

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន **ម៉េង ស្រ៊ាង** បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០២ គ្រនិង VHF ចំនួន ០៥ គ្រ ។

ប្រការ២ : ប្រកាសលេខ ២១១ និង ២១២ បទប្រកទអ ចុះថ្ងៃទី ១៤–១២–៩៤ ទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃណីយ៍ នាយកដ្ឋានផែនការគណៈនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង ក្រុមហ៊ុន **ម៉េង ស្រ៊ាង** ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ០២ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ០១៧ បទ.ប្រក

– រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

– បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញអនុក្រឹត្យលេខ០៥អនក្រ ចុះថ្ងៃទី០៥–៣–៨៧ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

– បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF របស់ក្រុមហ៊ុន ភែន អេស៊ា អ៊ិនធើ ណេស្សូណាល់ ខូអិលធីឌី ចុះថ្ងៃទី ១៩–០១–៩៦ ។

– ប្រកាសលេខ ១៩៨ បទប្រកទអ ចុះថ្ងៃទី ០១–១២–៩៤ ។

– សេចក្តីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ០៥–១០–៩៥ ។

សំរេច

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន ភែនអេស៊ាអ៊ិនធើណេស្សូណាល់ខូអិលធីឌី បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០៤ គ្រ ។

ប្រការ២ : ប្រកាសលេខ ១៩៨ បទប្រកទអ ចុះថ្ងៃទី ០១–១២–៩៤ ទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃណីយ៍ នាយកដ្ឋានផែនការគណៈនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេសនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង ក្រុមហ៊ុន ភែនអេស៊ាអ៊ិនធើណេស្សូ ណាល់ខូអិលធីឌី ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ០២ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ០១៨ បទ.ប្រក

- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង គណៈរដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រិត្យលេខ០៥អនក្រ ចុះថ្ងៃទី០៥-៣-៨៧ ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF របស់អង្គការ PACT លេខ ០៥៣២១០១ ចុះថ្ងៃទី ២០-០១-៩៥ ។
- ប្រកាសលេខ ១៨៥ បទប្រកទអ ចុះថ្ងៃទី ១១-១១-៩៤ ។
- សេចក្តីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ១១-១០-៩៥ ។

សំរេច

ប្រការ១ : អនុញ្ញាតអោយអង្គការ PACT បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០៥ គ្រឿង ។

ប្រការ២ : ប្រកាសលេខ ១៨៥ បទប្រកទអ ចុះថ្ងៃទី ១១-១១-៩៤ ទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃណីយ៍ នាយកដ្ឋានផែនការគណៈនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេសនាយកដ្ឋានទូរគមនគមន៍អន្តរជាតិ និង អង្គការ PACT ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ០២ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ០១៩ មឆ.ប្រក

- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រិត្យលេខ០៥អនក្រ ចុះថ្ងៃទី០៥-៣-៨៧ ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF & VHF របស់អង្គការ AICF/USA Cambodia លេខ ០១៦២១០១ ចុះថ្ងៃទី ១៣-០១-៩៦ ។
- ប្រកាសលេខ ១៧២ បទប្រកទអ និង ១៧៤បទប្រកទអ ចុះថ្ងៃទី ២៦.១០.៩៤ ។
- សេចក្តីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ០៥-១០-៩៥ ។

សំរេច

ប្រការ១ : អនុញ្ញាតអោយអង្គការ AICF/USA- CAMBODIA បន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ HF ចំនួន ០៣ គ្រ. និង VHF ចំនួន ០៥ គ្រ និង បន្ថែម ចំនួន ០៤ គ្រឿង ។

ប្រការ២ : ប្រកាសលេខ ១៧២ បទប្រកទអ និង ១៧៤ បទប្រកទអ ចុះថ្ងៃទី ២៦-១០-៩៤ ទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិនិង អង្គការ AICF/USA- CAMBODIA ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ០២ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ០២០ បគ.ប្រក

ស្តីពីការកំណត់បេឡារងជូនមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រុងព្រះសីហនុ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍
- ពិនិត្យសំណូមពរចាំបាច់ ស្តីពីការរីកចំរើន នៃការងារប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

សំរេច

ប្រការ១ : ត្រូវបានកំណត់បេឡារងបណ្តោះអាសន្នជូនមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រុង ព្រះសីហនុ ជាតែមប្រៃសណីយ៍ ដែលមានតម្លៃស្មើនឹងប្រាក់ចំនួន ប្រាំបួនរយពាន់រៀលគត់ (៩០០.០០០ រៀល) ។

ប្រការ២ : រាល់សេចក្តីសំរេចឬប្រកាសទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៣ : នាយកខុទ្ទកាល័យ លោកប្រធានអធិការកិច្ច លោកនាយកដ្ឋានចំណុះក្រសួង និង លោក ប្រធានមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ យោងតាមលិខិតស្នើសុំរបស់បដិគ្គាហកៈមន្ទីរ ប.ទ ក្រុងព្រះសីហនុ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ យុន

* * *

៧—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សេចក្តីសំរេច

ស្តីពីការបែងចែកនិស្សិតចំនួន ២៨ នាក់ ដែលទើបបញ្ចប់ការសិក្សា ក្រៅប្រទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨.០២.១៩៩៥

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រគីរិត ០១ ចំនួន ០១ នាក់ អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ២៦ នាក់ និងអ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០១ នាក់ ដែលបានបញ្ចប់ការសិក្សាពីក្រៅប្រទេសត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមក្រសួងស្ថាប័នមួយចំនួនដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជនចាប់ពីថ្ងៃដែលបានបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឡាក់ សុខ

* * *

តារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ១១៧ សសរ.មសប្រុខ ចុះថ្ងៃទី ០៩ ខែ ០២ ឆ្នាំ ១៩៨៦ ស្តីពីការបែងចែកសិស្ស និស្សិតចំនួន ២៨ នាក់ ដែលទើបបញ្ចប់ការសិក្សា ក្រៅប្រទេស

* * *

ល.រ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញបច្ចេកទេស	បៀវត្ស	ប្រភពបណ្តុះបណ្តាល

១— ក្រសួងទេសចរណ៍ចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

១	សេង ខា	ប	០៩.០៨.៦៨	សិស្ស	សេ.កិទេសចរណ៍សណ្ឋាគារ	៩០ខ I១	៣

២— ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទចំនួន ០៤ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៤ នាក់

២	សយ សុខឌុម	ប	១៦.១០.៦៣	សិស្ស	បសុព្យាបាល	៩០ខ I១	៥
៣	គូ គីមហាក់	ប	០១.០៦.៧០	-	កសិ.តំបន់ក្តៅ	-	៦

៤	ហង្ស សេរីវុឌ្ឍ	ប	០៥.០៨.៦៩	—	សេដ្ឋ.តាមនាវា	-	៤
៥	ហ៊ុម វិបុលឫទ្ធិ	ប	០៦.០៥.៦៥	—	រុក្ខកម្ម	-	៣

៣—ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពលចំនួន ០៣ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

៦	គីម ធីរូ	ប	១៦.០៥.៦៨	—	បច្ចេកវិជ្ជាអនុវត្ត សំភារៈច្នាស៊ីន	៩០ខ I១	១
៧	គីម កែវម៉ារ៉ា	ប	២៥.០៨.៦២	ប.លិក្រ.ឧស្សាហកម្មរ៉ែនិងថាមពល	បច្ចេកវិទ្យាគីមីសរីរាង្គ និងអសរីរាង្គ	ខ I១	២

ខ— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

៨	ជុំ សុពុទ្ធី	ប	១៣.០១.៦៧	បុគ្គ.មន្ទីរឧស្សាហកម្មខេត្តកំពង់ចាម	កំលើងនិងផ្គុំសុជល បរិក្ខារឧស្សាហកម្ម	ខ II១	១

៤—ក្រសួងសាធារណការ និង ដឹកជញ្ជូនចំនួន ០៩ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៩ នាក់

៩	ម៉ិញ សំអឿន	ប	០១.០៩.៥៩	បុគ្គ.សាធារណការនិងដឹកជញ្ជូន	ស្ថាបត្យកម្ម	ខ I១	៤
១០	ប៉ុល ថាវ័ន្ត	ប	១១.០៤.៦១	—	—	-	៤
១១	ធូ សំណាង	ប	២៩.១០.៦៣	បុគ្គ.ក្រ.គមនាគមន៍	សំណង់ផ្លូវគមនាគមន៍	-	២
១២	ឈឹម ដារិន	ប	១០.០២.៦៧	សិស្ស	សំណង់គ្រឿងម៉ាស៊ីន	៩០ខ I១	២
១៣	ទុន ចាន់ដារ៉ា	ប	២៩.០១.៦៨	សិស្ស	សេដ្ឋ.គ្រប់គ្រងផ្លូវដែក ផ្លូវថ្នល់	៩០ខ I១	១
១៤	ធុង វីរ៉ា	ប	០៥.១១.៧០	សិស្ស	ស្ថាបត្យកម្ម	-	៤
១៥	ភ៊ាហោង ដារុង	ប	២៣.០៤.៧១	សិស្ស	—	-	៤
១៦	ឆែត ពិសិដ្ឋ	ប	០១.០១.៧០	សិស្ស	—	-	៤
១៧	សុខ សុខុមវណ្ណា	ប	១៥.០៥.៦៧	សិស្ស	—	-	១

៥—ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រក៏រិត ១ ចំនួន ០១ នាក់

១៨	វណ្ណ សុវណ្ណទេវី	ស	១១.០៥.៦៧	សិស្ស	ទំនាក់ទំនងសេដ្ឋកិច្ច អន្តរជាតិ	៩០៩ I៤	៦

៦—ក្រសួងសុខាភិបាល ចំនួន ០៣ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៣ នាក់

១៩	អៀង កវី	ប	១៥.០៣.៦៤	សិស្ស	វេជ្ជសាស្ត្រ	៩០៩ I១	២
២០	កើត ផាន់ណារិទ្ធ	ប	០១.០១.៦៥	សិស្ស	–	-	៣
២១	យស សំណាង	ប	០៧.០៧.៦៧	សិស្ស	វេជ្ជសាស្ត្រទូទៅ	-	៤

៧—ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈចំនួន ០៤ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៤ នាក់

២២	ទេស ឈឿន	ប	០៣.០៤.៧០	បុគ្គ.សាលានយោបាយវប្បធម៌និងមុខជំនាញ	សារមន្ទីរ	៖ I១	៤
២៣	ឈុន សុខា	ស	០៣.០២.៦៣	សិស្សសាលាវិចិត្រសិល្បៈ	ជួសជុល និងថែរក្សាវត្ថុបុរាណ	៩០៩ I១	៣
២៤	ប៊ីន ណារ៉ា	ប	០៧.០៥.៦៥	–	–	-	៣
២៥	សំ ធីតា	ស	១៥.០៥.៦៧	បុ.ពិក្រសួងវប្បធម៌	សារមន្ទីរនិងវត្ថុបុរាណ	៖ I១	៤

៨—ក្រសួងមហាផ្ទៃចំនួន ០២ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

២៦	ឥន គី	ប	០៤.០៣.៦៦	សិស្ស	សំណង់ទីក្រុង	៩០៩ I១	៣
២៧	កែវ សុវណ្ណរិទ្ធ	ប	០៧.០១.៦៩	សិស្ស	សេ.កិ និងការគ្រប់គ្រងសំណង់	៩០៩ I១	១

៩— រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

២៨	អ៊ុង ទេពការុណ	ស	២៨.០១.៨៦	សិស្ស	អក្សរសិល្ប៍និងភាសារុស្ស៊ី	៩០៦ I១	១

បានបញ្ឈប់បញ្ជីត្រឹមចំនួន ២៨ នាក់

« ម្ភៃប្រាំបី » នាក់ប៉ុណ្ណោះ

កំណត់សំគាល់

១– សហព័ន្ធ រុស្ស៊ី

២– ប្រទេស អាល្លឺម៉ង់

៣– ប្រទេស ប៉ូឡូញ

៤– ប្រទេស វៀតណាម

៥– ប្រទេស ម៉ុងហ្គោលី

៦– ប្រទេស ឆេក្ហ

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៧៨០ រៀល